**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១០៩ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យសំណុំឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ដែលជនបរទេសកំពុងកាន់កាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៥/នស/៩៤ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីអន្តោប្រវេសន៍
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០៩៦/៣០ ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសញ្ជាតិ
- បានឃើញអនុក្រឹត្យលេខ ១០៩អនក្រ ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងលិខិតលេខ ៧៣៣សជណ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## <u>សម្រេច</u>

**ប្រការ១ៈ** ត្រូវបានបង្កើតក្រុមការងារអន្តរក្រសួង ដើម្បីពិនិត្យសំណុំឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ដែលជនបរទេសកំពុងកាន់កាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១- ឯកឧត្តមនាយឧត្តមសេនីយ៍ | **អ៊ុក គីមលេខ** | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | ប្រធាន |
| ២- ឯកឧត្តម | **កើត រិទ្ធ** | រដ្ឋលេខាធិការក្រសួងយុត្តិធម៌ | អនុប្រធាន |
| ៣- ឯកឧត្តម | **ស៊ា កុសល** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |

| | | | |
|---|---|---|---|
| **៤- ឯកឧត្តម** | **នូន ស៊ីផាន់** | អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ នៃទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| **៥- ឯកឧត្តម** | **ម៉ូលី ដា** | អនុរដ្ឋលេខាធិការក្រសួងមហាផ្ទៃ | អនុប្រធាន |
| **៦- ឯកឧត្តមនាយឧត្តមសេនីយ៍** | **សុខ ផល** | អគ្គនាយក នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| **៧- ឯកឧត្តមនាយឧត្តមសេនីយ៍** | **ថោង លីម** | អគ្គស្នងការរង នៃអគ្គស្នងការដ្ឋាននគរបាលជាតិ | សមាជិក |
| **៨- ឯកឧត្តមឧត្តមសេនីយ៍ឯក** | **សូ វ៉ាន់ធី** | អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន | សមាជិក |
| **៩- ឯកឧត្តម** | **ស្វ សុខខេង** | អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាល | សមាជិក |
| **១០- ឯកឧត្តមឧត្តមសេនីយ៍ឯក** | **សុខ ធី** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម | សមាជិក |
| **១១- ឯកឧត្តមឧត្តមសេនីយ៍ឯក** | **ធាង រ៉ាស៊ី** | អនុប្រធានក្រុមប្រឹក្សានីតិកម្ម នៃក្រសួងមហាផ្ទៃ | សមាជិក |
| **១២- ឯកឧត្តមឧត្តមសេនីយ៍ឯក** | **ឃុន សំបូរ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| **១៣- ឯកឧត្តមឧត្តមសេនីយ៍ឯក** | **ពិន ពិសិដ្ឋ** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |
| **១៤- ឯកឧត្តមឧត្តមសេនីយ៍ឯក** | **សុវណ្ណា ពិសាខា** | អគ្គនាយករង នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ | សមាជិក |

**១៥- ឯកឧត្តម លោកជំទាវ អគ្គនាយករងទាំងអស់ នៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍** សមាជិក

**ប្រការ២ :** ក្រុមការងារអន្តរក្រសួង មានភារកិច្ចដូចខាងក្រោម ៖

-ធ្វើផែនការសម្រាប់បម្រើឲ្យការស្រាវជ្រាវលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនានា និងពិនិត្យសំណុំឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ដែលជនបរទេសកំពុងកាន់កាប់ប្រើប្រាស់ក្នុងព្រះរាជាណាចក្រកម្ពុជា សំដៅឆ្លើយតបទៅនឹងសំណូមពរការងារ និងប្រកបដោយប្រសិទ្ធភាព។

-រៀបចំបែបបទ និងលិខិតបទដ្ឋានមួយចំនួន ដើម្បីដាក់ជូន**សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ពិនិត្យ សម្រេចមោឃៈភាពលើឯកសាររដ្ឋបាលកម្ពុជាមិនប្រក្រតី ដែលកាន់កាប់ដោយជនបរទេស តម្រូវឲ្យពួកគេទាំងអស់នោះអនុវត្តនីតិវិធីដាក់ពាក្យសុំជាជនបរទេសអន្តោប្រវេសន្ត។

-ធ្វើរបាយការណ៍បូកសរុបលទ្ធផលការងារ និងគោរពស្នើសុំគោលការណ៍ពិនិត្យសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។**

**ប្រការ៣ :** ក្រុមការងារអន្តរក្រសួងត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និងមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទ ដើម្បីជួយការងារតាមការចាំបាច់ ។

**ប្រការ៤ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងឯកឧត្តម លោកជំទាវ អស់លោកដូចមានក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសម្រេចនេះ អោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខា តទៅ។

រាជធានីភ្នំពេញ,ថ្ងៃទី១៧ ខែ កញ្ញា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល:**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ដូចប្រការ ៤
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ